# មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0091

## សម្ភាសន៍ជាមួយឈ្មោះ ឡឿ លឿម ភេទប្រុស អាយុ៥៩ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ សេនាជនភូមិ
## សព្វថ្ងៃរស់នៅភូមិជន្លៀសដៃ ឃុំគោកកថិន ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ ហ៊ិន សុធានី
## ០០:៤០:១០
## ២១ទំព័រ

ធានី ៖ ថ្ងៃនេះថ្ងៃទី១៧ ខែ១២ ឆ្នាំ២០១០ ។ ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជាលោកតា ហើយខ្ញុំចុះមកនេះគ្រាន់តែចង់សាក់សួរពីប្រវត្តិរបស់លោកតា តាំងពីមុនរហូតមកដល់ឥឡូវ តើលោកតាបានជួបលំបាកអីខ្លះ ឬក៏មានរឿងហេតុអីខ្លះដែលលោកតាបានឆ្លងកាត់ចឹង ។ ហើយប្រវត្តិទាំងអស់នេះ ពួកខ្ញុំសុំយកមកសរសេរជាសៀវភៅ ក៏ដូចជាសម្រាប់ក្មេងៗ និងអ្នកស្រាវជ្រាវផ្សេងៗបានសិក្សារៀនសូត្រ ។ ឲ្យយកមកប្រើប្រាស់ចឹងបានទេ លោកតា?

លឿម ៖ បាន ។

ធានី ៖ ចឹងខ្ញុំសុំថតជាសម្លេង ក៏ដូចជាថតជារូបថតចឹងបានទេ?

លឿម ៖ បាន ។

ធានី ៖ លោកតាមានឈ្មោះអីដែរ?

លឿម ៖ ឈ្មោះ ឡឿ ។

ធានី ៖ ឡឿន?

លឿម ៖ ឡឿ លឿម ។

ធានី ៖ ឡឿ លឿម?

លឿម ៖ បាទ!

ធានី ៖ លោកតាឆ្នាំហ្នឹងអាយុប៉ុន្មានហើយ?

លឿម ៖ ខ្ញុំ៥៩ ។

ធានី ៖ ៥៩ លោកតាមានស្រុកកំណើតនៅណាដែរ?

លឿម ៖ បាទ! ខ្ញុំមានស្រុកកំណើតនៅភូមិជន្លៀសដៃនេះ ។

ធានី ៖ ភូមិជន្លៀសដៃ?

លឿម ៖ បាទ!

ធានី ៖ ជន្ទៀសដៃ ឃុំអីដែរលោកតា?

លឿម ៖ បាទ! ដូចសព្វថ្ងៃនេះ មានឃុំគោកកបិននេះ ។

ធានី ៖ ស្រុកអីគេដែរលោកតា?

លឿម ៖ ស្រុកថ្មពួក ។

ធានី ៖ ខេត្ត?

លឿម ៖ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ចឹងលោក ស្រុកកំណើតក៏នៅហ្នឹង ហើយសព្វថ្ងៃក៏លោកតារស់នៅហ្នឹងដែរ?

លឿម ៖ បាទ! សព្វថ្ងៃរស់នៅហ្នឹង ។

ធានី ៖ ឪពុកលោកតាឈ្មោះអីគេទៅ?

លឿម ៖ ឈ្មោះ ឡឿ ដាំង ។

ធានី ៖ ឡឿ ដាំង?

លឿម ៖ បាទ! ដាំង ។

ធានី ៖ គាត់នៅរស់ទេ?

លឿម ៖ អត់ទេ ស្លាប់ហើយ ។

ធានី ៖ ស្លាប់ពេលណាដែរ?

លឿម ៖ ស្លាប់ខ្វង់ យេ៎!១៩៧៥ ។

ធានី ៖ ១៩៧៥ ដោយសារអីដែរលោកតា?

លឿម ៖ គាត់ឈឺ ។

ធានី ៖ ចុះម្ដាយ?

លឿម ៖ ម្ដាយងឹនៗ វែល ។

ធានី ៖ ងឹន វែល?

លឿម ៖ បាទ! វែល ។

ធានី ៖ គាត់ស្លាប់ហើយ?

លឿម ៖ ស្លាប់ហើយ ។

ធានី ៖ ពេលណាដែលលោកតា?

លឿម ៖ ស្លាប់ឆ្នាំ ៨៣ ។

ធានី ៖   ដោយសារអីដែរ?

លឿម ៖ ជម្ងឺ ។

ធានី ៖   ឈឺអីដែរ?

លឿម ៖ ជម្ងឺធម្មតាយើង ។

ធានី ៖   ចុះលោកពុកលោកតាចឹងដែរ?

លឿម ៖ បាទ! ដូចគ្នា ។

ធានី ៖   ឈឺធម្មតា?

លឿម ៖ ថារោគ ពិតមែនថារោគស្អីទេ អារឿងរោគ ។

ធានី ៖   លោកតាមានបងប្អូនប៉ុន្មាននាក់?

លឿម ៖ ខ្ញុំរស់នៅ៧នាក់ ។

ធានី ៖   បងប្អូន៧នាក់?

លឿម ៖ បាទ!

ធានី ៖   ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

លឿម ៖ ស្រី៤ ប្រុស២ ។

ធានី ៖   ស្រី៤ ប្រុស២ម៉េច?

លឿម ៖ អឺ! ស្រីដល់៥នាក់ ។

ធានី ៖   ស្រី៥ ប្រុស២?

លឿម ៖ ៧ ។

ធានី ៖   ហើយនៅរស់រាល់ថ្ងៃប៉ុន្មាននាក់?

លឿម ៖ អត់ទេ ខ្ញុំសព្វថ្ងៃនៅរស់២នាក់នេះឯង ។

ធានី ៖   នៅរស់តែ២នាក់ហ្នឹង?

លឿម ៖ បាទ!

ធានី ៖   ចឹងស្លាប់អស់៥ហើយ?

លឿម ៖ បាទ!

ធានី ៖   ស្លាប់ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

លឿម ៖ ស្លាប់ស្រី៤ ប្រុស១ ។

ធានី ៖   ស្រី៤ នៅសល់លោកតាមួយ និងបងស្រីមួយ?

លឿម ៈ បាទ! សល់ប៉ុនហ្នឹង ។

ធានី ៈ លោកតាជាកូនទីប៉ុន្មាន?

លឿម ៈ ខ្ញុំកូនទី៥ ទី៦ ។

ធានី ៈ ជិតពៅដែរ?

លឿម ៈ បាទ!

ធានី ៈ ហើយបងស្រី?

លឿម ៈ បងស្រីកូនទីៗ៤ ។

ធានី ៈ លោកតាបានរៀនដល់ថ្នាក់ទីប៉ុន្មានហើយ?

លឿម ៈ រៀនចូលបានថ្នាក់ទី៨យើង ទី៨ ទី៩ ។

ធានី ៈ ថ្នាក់ទី៨ៗ ចាស់នៅសាលាណាទៅកាលហ្នឹង?

លឿម ៈ បាទ! ខ្ញុំរៀននៅសាលាទ្រាស ។

ធានី ៈ សាលាទ្រាស?

លឿម ៈ ទ្រាសយើង ផ្ទះតាសៀវ ផ្ទះគោកកបិន តាសៀវ ។

ធានី ៈ សាលាផ្ទះ ឬក៏សាលាយើង?

លឿម ៈ បាទ! អាសាលាយើងធម្មតា ។

ធានី ៈ អូ! ជិះពីនេះទៅឃើញសាលារៀនមួយហ្នឹង?

លឿម ៈ បាទ! អាហ្នឹងខ្មែរយើងអាសាលាសសរនេះ ប៉ុនយើងវ៉ៃក្តារ ស័ង្កសី ។

ធានី ៈ គេហៅសាលាទ្រាសចឹង?

លឿម ៈ បាទ! ហៅសាលាទ្រាស ។

ធានី ៈ ហើយបន្ទាប់មកទៀត ម៉េចបានលោកតាឈប់រៀន?

លឿម ៈ កាលហ្នឹងដូចខ្ញុំ មើលដល់អាពេលគេវ៉ាកង់ក៏ខ្ញុំមកផ្ទះៗបេះ មកផ្ទះគ្រូតាមហៅទៅវិញដែរ តែខ្ញុំអត់បានទៅ ។ ខ្ញុំទើបរៀនចូលថ្នាក់ទី៩ ទី៨ ដល់មកគ្មានអ្នកណាមើលគោមើលក្របីគេ ទៅស្រុកស្រែគ្រប់គ្នា ។ កាលនោះបើសិនជារៀនតស៊ូកាលនោះក៏មិនបានយូរប៉ុន្មាន បានចប់ថ្នាក់ទី៩ ព្រោះកាលៈទេសៈនោះចូលដល់សម័យគេហៅយួនយៀកកុង ។ ដល់អស់អាយួនយៀកកុងទៅក៏ចូលខ្មែរក្រហមថាប៉ុលពតៗ ខ្មែរក្រហម ។ បានខ្ញុំឈប់ទៅមុខ បានខ្ញុំបួសៗបាន២វស្សាៗបានដាក់គេចូលសម័យពេញសិទ្ធិនោះខ្លាំង ចូលសម័យរំដោះ ខ្ញុំក៏អត់បានទៅណាទៅណៃ បានខ្ញុំក៏ទៅពីនោះទៀតបម្រើម៉ែឪធ្វើស្រែចំការស៊ីតែប៉ុនហ្នឹង អត់បានទៅណា៎ ។

ហើយចូលសម័យ៣ឆ្នាំ  វារបស់អីកាលនោះវាអត់មានច្បាប់ដើរហើរទៅណាផង  ហើយគេក៏មិនមានសិទ្ធិឲ្យនិយាយទាមទារតវ៉ានេះនោះផង  ក៏ខ្ញុំទៅជាអសកម្មបំបិទសិទ្ធិខ្ញុំចោល  ខ្លួនខ្ញុំគ្មានស្អីទៅណាទៀតផង ។  កាលហ្នឹងបើកាលណាយើងបង្ហាញខ្លួនយើង  អាចថាយើងដឹងយើងផ្ទុះធ្លាយទៅទៀត  យើងទៅវាអត់រួច  យើងការពារខ្លួនយើងដែរ  បើយើងមិននេះខ្លាចដែរ ។  ចុះយើងគ្មានសិទ្ធិទាមទារតវ៉ាអីអត់បានផង  ដល់យើងការខុសឆ្គងអីទៅយើងអត់មានសិទ្ធិទៅនឹងទេ  និយាយតវ៉ាស្អីក៏មិនបាន ។  ចុះគេ  ប្រើអជ្ញាហឹង្សាហើយ  គឺអត់បានមានទាល់តែខ្ញុំ ។  ខ្ញុំក៏កាលពីដើមមិញ  ក៏ខ្ញុំមិនទាន់ថាចង់បានគ្រួសារអីដែរក៏ខ្ញុំមិនទាន់ចង់បាន ។  ទើបមកសម័យឥឡូវទើបវាយ៉ាប់យឺន  មានអ្នកណាគ្រប់គ្រងបងប្អូន  ម៉ែឪខ្ញុំៗក៏បានជាយកគ្រួសារហ្នឹង ។  ហើយខ្ញុំមិនបានទៅណាទៅណែនឹងគេទេយកគ្រួសារ ។  កាលនោះអាយុខ្ញុំទើប២៣ ២៤នេះ ឯងហ្នឹង ។ បាទ! ហើយទល់រហូតមកដល់ខ្មែរក្រហម គេនាំខ្ញុំទៅធ្វើខ្មែរក្រហម ខ្មែរអីខ្ញុំទៅ ធ្វើសេនាជនសេនាអីណាខ្ញុំមិនទៅ ។ ខ្ញុំចេះតែគិតវែងឆ្ងាយខ្លួនខ្ញុំប៉ុនគេបង្ខែបង្ខំខ្ញុំដែរ ប៉ុនខ្ញុំអត់ទៅ ខ្ញុំមើលកាលៈទេសៈនោះវាអត់គួរទៅ ។ ប៉ុនខ្ញុំមិននិយាយខ្ញុំអត់និយាយទេ  ខ្ញុំសុខចិត្តកាន់ក្នុងទុកពោះខ្ញុំ  ខ្ញុំធ្វើមិនធ្វើមិនប្រើ  អ្នកណាថាអ្នកណាខ្ញុំមិនមានពាក្យត ។  ហើយខ្ញុំក៏ចេះសង់ៗមកសព្វថ្ងៃនេះ ។  ប៉ុន្តែខ្ញុំចេះតែជួយបម្រើគេ  ខ្ញុំមិនប្រកែកប្រណាំងប្រជែងអីគេទេ  ក៏អត់មាត់ដែរ  ប្រណាំងប្រកែកទេ ។  គេប្រើទៅណាទៅពលកម្មណាខ្ញុំចេះតែទៅៗណាចេះតែទៅ  បើខ្ញុំមិនស្រួលអីចេះទៅ  ក៏ខ្ញុំស្នើប្រាប់គេតាមត្រង់បើគេប្រកាន់ខឹងមិនដឹងធ្វើម៉េច  បើគេមិនប្រកាន់ខ្ញុំក៏បានរស់បានរៀនចេះ ។  បើសិនគេប្រកាន់ បើខ្ញុំទៅធ្វើញ៉ើញុងដាក់គេ ខ្ញុំកម្រើកខ្លួនមិនរួចដែរ ។ ដល់ហើយទៅខ្ញុំធ្វើតាមដំណើរទៅ ធ្វើល្ងង់ខ្លះដាខ្លះ ភូតខ្លះ ប៉ុន យើងមិនមែនបណ្តោយឲ្យអត្តចរិតយើងឲ្យវាហួសហេតុពេកក៏ខ្ញុំមិនដឹង ខ្ញុំទៅតាមដំណើររបស់ខ្ញុំ ។ ចឹងបានរស់នៅប៉ុននេះ ហើយចូលតាមសង្គមចេះក៏ខ្ញុំជួយបម្រើសព្វគ្រប់យ៉ាង ហ៎! ខាងរដ្ឋកម្ពុជាយើងនេះ ក៏ខ្ញុំជួយអស់សមត្ថភាពដែរក-៥ក៏ខ្ញុំទៅវរសេនាជនក៏ខ្ញុំធ្វើ ហ៎!ក្រុម ក៏ខ្ញុំធ្វើទៀត ខ្ញុំនៅទឹកដីបាត់ដំបង១០ឆ្នាំ បានខ្ញុំបកត្រឡប់មកនេះវិញ ។ បើសិនណាម្តាយខ្ញុំ កុំឈឺក៏ខ្ញុំមិនបានបកមកនេះវិញដែរ ហើយខ្ញុំនៅដីបាត់ដំបងបាត់ ។ ប៉ុនដល់ពេលម្តាយខ្ញុំឈឺ គេមិនចង់ឲ្យខ្ញុំមកវិញទៀតផង ប៉ុនខ្ញុំតើចេះជំនះខ្ញុំថាម្តាយទាំងមូល ហើយខ្ញុំក៏បានចេះដឹង អារឿងធម៌អាទិ៍តិចតួចដែរ បើយើងល្មើសគុណម្តាយក៏វាមិនកើតសុំច្បាប់គេមក គេមិនចង់ឲ្យខ្ញុំមកទៀត ។ មកដល់នគរបាលគេចាប់ហ្នឹងទៀត ចាប់ហ្នឹងបាត់ដំបងទៀត ចុះអាប្អូននោះ វាបានទ្រនាបជើងខ្មែរក្រហមមកវាយកមក

ឲ្យខ្ញុំពាក់ៗ ដល់ពេលខ្ញុំពាក់ គេឃើញទ្រនាប់ជើង ខ្ញុំគេឲ្យមិនចង់ឲ្យមកទៀតៗ ទាល់តែខ្ញុំហួតក្រដាសពីហោប៉ៅឲ្យគេមើលបានគេឲ្យខ្ញុំបានគេឲ្យខ្ញុំបាន ហើយអាសំបុត្រដែលខ្ញុំត្រូវមកពីនោះ គេដកយកវិញអស់ បានខ្ញុំថានេះអន់ចិត្ត ប៉ុន្តែខ្ញុំមិនហ៊ាននិយាយគេៗកំពុង...ដាក់ខ្ញុំចេះនោះៗ ប៉ុន្តែខ្ញុំថា...ថាឲ្យខ្ញុំទៅណាក៏មិនមានដែរ បានខ្ញុំបកមកវិញមកសម្រាកនៅស្វាយចេកៗ ស្នាក់នៅស្វាយចេកក៏មានគេថាខ្ញុំជនទុរភិក្ស ជួនអីណាក៏ដោយខ្ញុំថាជនទុរភិក្សម៉េចមនុស្សមកពីក្នុងគ្រប់មកថាជនទុរភិក្សៗ ខ្ញុំៗថាមិនមែនទេ បានខ្ញុំក៏ដកលុយសម័យយើង៥០០០រៀល ឲ្យទៅមេឃុំខ្ញុំ ឲ្យថាគ្រាប់ហួបគុយទាវទៅខ្ញុំគ្មានស្អីឲ្យៗ ហើយដល់សង្គមក្រោយៗខាងណាក៏ខ្ញុំមិនទាស់ៗ ខ្ញុំជួយសព្វហ៎!មកខាងនេះសន្តិសុខ ប៉ាំរ៉ាខ្ញុំជួយដែរ កាលនោះខ្លួនខ្ញុំវានៅមិនទាន់ដល់អាយុពេញប៉ុននេះៗ កាលនោះខ្ញុំត្រឹម៣០ទេ អត់ទាន់៤០ ដល់៥០ទេ បានខ្ញុំជួយមករបូតដល់ស្រុកសន្តិភាពៗ

ធានី ៖ ចឹងលោកតាកាលពេលបួសនៅវត្តហ្នឹង បួសនៅវត្តណាដែរ?

លឿម ៖ បាទ! វត្តទ្រាសដែរៗ

ធានី ៖ លោកតាបួសបាន២វស្សា ឈប់បួសទៅណាវិញ?

លឿម ៖ បាទ! សឹកមកផ្ទះៗ

ធានី ៖ សឹកមកផ្ទះ?

លឿម ៖ បាទ! អត់បានទៅណាទេៗ

ធានី ៖ នៅឆ្នាំប៉ុន្មាន បួសហ្នឹងឆ្នាំប៉ុន្មាន?

លឿម ៖ អឺ! តាំងយូរហើយ ឆ្នាំ....ព្រោះវាចូលសម័យកាលនោះឆ្នាំ១៩០០ពាក់ថា៥០ ៦០ហើយមើលសម័យសាធារណរដ្ឋៗ

ធានី ៖ ឆ្នាំ១៩៦០?

លឿម ៖ បាទ!

ធានី ៖ ចុះលោកតាពេលដែលក្រោយមកទៀត លោកតាថាសម័យរំដោះពេញសិទ្ធិ មិនពេញសិទ្ធិអាហ្នឹងសម័យណា?

លឿម ៖ អាសម័យរំដោះពេញសិទ្ធិហ្នឹង សម័យខ្មែរក្រហមហ្នឹងដែលវាមិនពេញសិទ្ធិយើងៗ

ធានី ៖ ឆ្នាំប៉ុន្មាន លោកតាអាចដឹងទេ?

លឿម ៖ អាហ្នឹងឆ្នាំ១៩៧៣ ៧៤ៗ

ធានី ៖ ៧៣ ៧៤?

លឿម ៖ បាទ!

ធានី ៖ កាលហ្នឹងលោកតានៅណា?

លឿម ៖ បាទ! ខ្ញុំនៅហ្នឹង ។

ធានី ៖ នៅហ្នឹងដែរ?

លឿម ៖ បាទ!

ធានី ៖ អាពេលហ្នឹងខ្មែរក្រហមចូលពេញ?

លឿម ៖ បាទៗ ចូលគេរំដោះបានចូល ។

ធានី ៖ ពេលហ្នឹងលោកតាមានចូលបដិវត្តហ្នឹងគេ?

លឿម ៖ ចូល ។

ធានី ៖ ចូលឆ្នាំប៉ុន្មាន?

លឿម ៖ ចូលហ្នឹង៧៥ហ្នឹងឯង ។

ធានី ៖ ១៩៧៥ ធ្វើបដិវត្ត?

លឿម ៖ អឺ!

ធានី ៖ ចូលជាមួយអ្នកណាគេ?

លឿម ៖ ទេ! ចូលហ្នឹងមិនបានទៅណាទេ បាទ! គឺចូលភូមិករយើងពេលចូលមកវិញហើយ ។

ធានី ៖ តែលោកតា មានបានចូលធ្វើបដិវត្តជាមួយខ្មែរក្រហមអត់?

លឿម ៖ ខ្ញុំអត់បានចូលហ្នឹងគេទេ ខ្ញុំអត់បានចូល ។

ធានី ៖ ចុះ១៩៧៥ ខ្មែរក្រហមពេញទី?

លឿម ៖ បាទ! គេរំដោះបានអស់ហើយ ។

ធានី ៖ ហើយពេលហ្នឹងនៅភូមិលោកតាម៉េចដែរ?

លឿម ៖ ភូមិ កាលនោះភូមិគេរំដោះពីកើត ។

ធានី ៖ ពេលហ្នឹងម៉េចលោកតាឃើញម៉េចដែរ ពេលខ្មែរក្រហមចូលមកដល់ដំបូង?

លឿម ៖ វាមិនមានម៉េចទេ ប៉ុនគេរំដោះភូមិភាគយើងទៅអស់ អត់មានម៉េចទេ មកដល់ភ្លាមមានតែគេ រៀបៗជាពួករៀបជាក្រុមភូមិណា៎ៗ ។

ធានី ៖ លោកតាដល់ចឹងភូមិដន្លៀសដៃយើង កកើតយូរហើយ?

លឿម ៖ បាទ!

ធានី ៖ យូរហើយៗពេលដែលខ្មែរក្រហមចូលមកដល់ ក៏គេចាប់ផ្តើមមានជាភូមិជាក្រុមបន្ត?

លឿម ៖ បាទ! ហ្នឹងហើយ ។

ធានី ៖ តែម្តុំយើងនេះសំបូរព្រៃទេ ឬក៏វាចឹង?

លឿម ៖ បាទ! កាលនោះព្រៃយើងនៅខាងជើងភូមិ អាព្រៃស្រែយើង ។

ធានី ៖ នៅក្បែរកន្លែងហ្នឹងដែរតើលោកតា?

លឿម ៖ បាទ! ព្រៃស្រែយើងខាងជើងភូមិនេះដែរ ។ ដល់ពេលគេចែកភូមិ ដល់ពេលដែលចូលសម័យ នោះយើងតើបានដជែកគ្នា ទើបផ្លាស់ស្រែចំការ ពីដើមមិញគេផ្លាស់ស្រែចំការដែរ វាអត់ ដល់...ទេ ទើបប៉ុន្មានឆ្នាំផ្លាស់វាដល់លើនោះ ។

ធានី ៖ ចឹងលោកតាកាលសម័យ៣ឆ្នាំ លោកតាធ្វើអីគេ មុខងារ ធ្វើអីគេ?

លឿម ៖ បាទ! ខ្ញុំគ្មានធ្វើស្អីទេ ធ្វើតែនេះគេប៉ុននោះឯង លើកតែដី លើកតែស្អីគេ ធ្វើស្អីមានតែធ្វើ អាងៗនេះមានស្អីមានតែធ្វើអាង ។

ធានី ៖ អាងអីគេ?

លឿម ៖ អឺ!អាង

ធានី ៖ អាងអីគេ?

លឿម ៖ អាងតាម៉េងយើង ។

ធានី ៖ អាងតាម៉េង?

លឿម ៖ បាទ! ហ្នឹងឯងមានតែអាងតាម៉េង ។

ធានី ៖ ចឹងអាងតាម៉េងហ្នឹងមានតាំងពីសម័យខ្មែរក្រហមមក?

លឿម ៖ បាទ! សម័យខ្មែរក្រហម ។

ធានី ៖ លោកតាអ្នកជីកនាំជីកអាងហ្នឹង?

លឿម ៖ អត់ទេ ខ្ញុំកូនក្រុម ។

ធានី ៖ កូនក្រុមខាងណាវិញ?

លឿម ៖ កូនក្រុម មេក្រុមខ្ញុំមានតែតាល្ងួនៗ ឈ្មោះតាល្ងួនៗ ។

ធានី ៖ ចឹងលោកតាសមាជិកក្រុមហ្នឹង?

លឿម ៖ អត់ទេ ខ្ញុំកូនក្រុម ។

ធានី ៖ កូនក្រុមម៉ង?

លឿម ៖ បាទ! កូនក្រុមគេ ។

ធានី ៖ ជាអ្នកជីកអាងហ្នឹង?

លឿម ៖ បាទ! គេដឹកនាំជីកអាងជីកអីម៉ាភូមិហ្នឹង ។ ប៉ុនក្នុងភូមិហ្នឹងដែរ ប៉ុនគេមានក្រុម គេចែកជាក្រុមៗគេ ។

ធានី ៖ ហើយអាងហ្នឹង ចឹងគេជីកត្រឹមម៉ានដល់ត្រឹម អាងហ្នឹង លោកតាដឹងទេ?

លឿម ៖ បាទ! ជីកតាំងពីនេះមកហ្នឹងណា ជីកពីចំងាយតាំងពីគោកកថិននេះមក ។ អាគោកកថិននេះទើបក្រោយទេ ចាប់ត្រឹមផ្ទះដែលនៅហ្នឹងហើយ អាលូដែលលិចហ្នឹង បានចាប់លើកពីខាងលិចមក ។

ធានី ៖ ហើយប៉ុន្មានម៉ែត្រទៅតា?

លឿម ៖ ដឹងប៉ុន្មានម៉ែត្រ ខ្ញុំភ្លេចបាត់ហើយ ចាំអត់បាន មិនបានជាចំណាំអារឿងត្រង់នោះផង ។

ធានី ៖ អ្នកណាគេអ្នកដឹកនាំជីកអាងហ្នឹងលោកតា?

លឿម ៖ គេសហករណ៍គេ ។

ធានី ៖ សហករណ៍គេឈ្មោះអីគេ?

លឿម ៖ សហករណ៍ឈ្មោះ តានាំៗ ។

ធានី ៖ តានាំ?

លឿម ៖ បាទ!

ធានី ៖ តានាំហ្នឹង ប្រធានសហករណ៍អីគេ?

លឿម ៖ ចុះសហករណ៍គេកាន់ក្នុងភូមិក្នុងឃុំ ។

ធានី ៖ ឈ្មោះភូមិសហករណ៍អីគេ?

លឿម ៖ តានាំៗ ។

ធានី ៖ អត់ទេ ចង់និយាយថាប្រធានសហករណ៍ហ្នឹងគេហៅសហករណ៍អីគេ?

លឿម ៖ កាលនោះ ឃុំថ្កាំ ។

ធានី ៖ តានាំហ្នឹងអ្នកដឹកនាំជីកប្រឡាយ?

លឿម ៖ បាទ! ហ្នឹងឯងដឹកនាំគាត់កាន់ខុទ្ទាហរណ៍ថាគាត់កាន់ក្នុងម៉ាឃុំយើងមានប៉ុន្មានភូមិ គាត់ដឹកនាំធ្វើ ។

ធានី ៖ កាលហ្នឹងជីកប្រឡាយប៉ុន្មានភូមិ?

លឿម ៖ ៨ ៩ ១០ឃុំណា៎ អឺ!១៩ភូមិ ។

ធានី ៖ ១៩ភូមិជីកនៅថ្កាំហ្នឹង អឺ!ជីកនៅដីអាងតាម៉េង?

លឿម ៖ បាទ! ដីអាងតាម៉េង ។

ធានី ៖ ម៉េចបានគេដាក់ឈ្មោះអាងតាម៉េង?

លឿម ៖ ព្រោះអូរតាម៉េង គេហៅតាម៉េងៗ ដល់យើងធ្វើអាងទៅបានអាងតាម៉េងបណ្តោយ ។

ធានី ៖ ចឹងបានន័យថាកន្លែងហ្នឹងពីអូរចាស់?

លឿម ៖ បាទ! អូរចាស់ អាកន្លែងដាច់ថ្មីៗ ដើមឬស្សីហ្នឹង សុទ្ធតែអូរចាស់ ។

ធានី ៖ អូរចាស់ចឹងទៅ?

លឿម ៖ ហ្នឹងមុនហ្នឹងធ្វើជាទំនប់មុន កាលពីសម័យបងៗខ្ញុំនៅអឺមុនហ្នឹងធ្វើកាត់អាង ។ អឺ! ធ្វើកាត់អូរហ្នឹងធ្វើកាត់អូរ ។ ដល់ពេលសម័យចូលសម័យ៣ឆ្នាំមក បានគាទាំហ្នឹង គាត់គម្រោងការមុនវិញថា ប្រុងយកទៅភ្នំនេះ មើលទៅវាវៀងឆ្ងាយអស់ស្រែចំការខ្ទាចវាលិចអ្នកផ្តាំផង ដល់ហើយបានកាត់មកចេះ ។

ធានី ៖ គេមើលតាម?

លឿម ៖ បាទ! គេមើលតាមកាលៈទេសៈ វាខាតស្រែចំការវាច្រើន ។

ធានី ៖ លោកតា គេជីកអាងតាម៉េងហ្នឹងជីករហូត ឬមួយខែវស្សាអត់ជីកទេ?

លឿម ៖ បាទ! ជីកតែម៉ាប្រាំងហ្នឹង ។

ធានី ៖ ជីកម៉ាប្រាំង ចុះខែវស្សាធ្វើអីគេ?

លឿម ៖ ខែវស្សាធ្វើស្រែ ។

ធានី ៖ ធ្វើស្រែដែរ ធ្វើស្រែនៅណា?

លឿម ៖ ធ្វើស្រែតាមវាលយើងនេះ តាមវាលយើងនេះ ។

ធានី ៖ តាមវាលយើង?

លឿម ៖ បាទ! តាមវាលខាងត្បូងនេះ អត់មានបានទៅធ្វើណាណៃតិចទេ ហើយព្រែកហ្នឹងក៏អត់បាន (ខ្យល់ខ្លាំងស្តាប់មិនបាន) ។

ធានី ៖ ចឹងធ្វើស្រែរហូត?

លឿម ៖ បាទ!

ធានី ៖ ចុះក្រៅពីប្រធានសហករណ៍មានអ្នកណាលើគាត់ហ្នឹងទៀតទេ?

លឿម ៖ អត់ទេ គ្មានអ្នកណាទៀតទេ មានតែដុតមកទៅមានតែការផ្លាស់ប្តូរប៉ុននោះឯង ។

ធានី ៖ ចុះគណៈស្រុកអី លោកតាស្គាល់ មានគាត់?

លឿម ៖ គណៈស្រុកគាត់នៅថ្មពួក ។

ធានី ៖ ហ្នឹងឈ្មោះអីគេ?

លឿម ៖ ខ្ញុំមិនស្គាល់ទេ ឈ្មោះគាត់ទេ ។

ធានី ៖ ចុះលោកតាដឹងថាតំបន់ហ្នឹងហៅតំបន់លេខប៉ុន្មាន?

លឿម ៖ តំបន់៥ ។

ធានី ៖ តំបន់លេខ៥ អ្នកណាគេអ្នកគ្រប់គ្រង?

លឿម ៖ បាទ! ខ្ញុំមិនដឹងទេ ខ្ញុំអត់ដឹងផង អារឿងទាំងនោះ ព្រោះគេនៅតែក្រុងៗនោះ ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែតំបន់៥ ។

ធានី ៖ ចុះលោកតាមុនហ្នឹង លោកតាដឹកធ្វើស្រែ ចុះពេលណារៀបគ្រួសារនោះ?

លឿម ៖ ខ្ញុំមានគ្រួសារទើបសម័យ៧៦ ។

ធានី ៖ ៧៦ហ៎?

លឿម ៖ បាទ!

ធានី ៖ ៧៦ រៀបគ្រួសារ?

លឿម ៖ បាទ!

ធានី ៖ រៀបនៅណាវិញ?

លឿម ៖ បាទ! ក្នុងភូមិ ។

ធានី ៖ នៅភូមិយើង?

លឿម ៖ បាទ! កាលនោះសម័យនោះ ក៏មិនមានបានម៉ាគូៗណា ។

ធានី ៖ ប៉ុន្មានគូកាលហ្នឹង?

លឿម ៖ សុទ្ធតែ២០ ទៅ១៥ ។

ធានី ៖ លោកតាកាលហ្នឹងរៀបប៉ុន្មានដែរ?

លឿម ៖ ច្រើនឯង កាលនោះ២០ ។

ធានី ៖ ២០គូ?

លឿម ៖ បាទ!

ធានី ៖ ហើយកាលហ្នឹងអ្នកណាគេ អ្នកដឹកនាំ?

លឿម ៖ នេះចំមេភូមិសព្វថ្ងៃនេះ ការជាមួយខ្ញុំ ។

ធានី ៖ មេឃុំគារៀបដែរ?

លឿម ៖ បាទ!

ធានី ៖ រៀបជាមួយលោកតាហ្នឹង?

លឿម ៖ ទេ! មេឃុំគេក៏រៀបជាមួយខ្ញុំដែរ ។

ធានី ៖ ឈ្មោះអីគេ?

លឿម ៖ សឿម ។

ធានី ៖ សឿម មេឃុំអីគេ?

លឿម ៖ ឃុំគោកកថិនសព្វថ្ងៃ ។

ធានី ៖ មេឃុំអីគេ សឿម?

កូនស្រី ៖ ស៊ឹម ។

ធានី ៖ មេឃុំគោកកថិន រៀបគ្រួសារជាមួយពូដែរ?

លឿម ៖ បាទ!

ធានី ៖ គ្រួសារពូឈ្មោះអីគេ អុំ?

លឿម ៖ ឈ្មោះ ហួន ។

ធានី ៖ អីគេ ហួន?

លឿម ៖ ជុំ ហួន ។

ធានី ៖ ហើយកាលហ្នឹងលោកតាមានស្នើអីហ្នឹងគេដែរ បាន?

លឿម ៖ បានស្នើតើ ។

ធានី ៖ ស្នើគាត់ ឃើញគាត់ស្នើ?

លឿម ៖ បាទ! ហ្នឹងហើយស្នើ ប៉ុនគេបាននៅនេះទៅ ប៉ុនគ្រួសារខ្ញុំ ស្រុកគេនៅបាត់ដំបង ប៉ុនដល់លោកពុកគាត់នោះធ្វើទាហាន ។ ដល់ប្រាប់ កាលពេលសម័យនោះគេបញ្ជូនគាត់ទៅវៃកោះកុង ដល់បាត់ខ្លួនៗ បានគេជម្លៀសម្ដាយក្មេកខ្ញុំមកនៅនេះ ។ ហើយជម្លៀសម្ដាយខ្ញុំមកនៅនេះដល់ធ្វើស្រែធ្វើចំការ ហើយដល់នៅៗក៏ស្នើ... ។

ធានី ៖ ចឹងលោកតាពេល លោកតាថាបម្រើគេៗប្រើឲ្យធ្វើអីធ្វើអត់តមាត់ហ្នឹង អ្នកណាគេ អ្នកណាប្រើ?

លឿម ៖ អឺ! ដូចក្រុម ដូចសហករណ៍អីគេប្រើទៅណាទៅអី គេប្រើទៅអុីទៅពលកម្មណាយើងចេះទៅ ហ្នឹងគេណា យើងទៅមានការទាមទារតវ៉ាអី ។ បើយើងថាទេ ខ្ញុំមិនទៅទេ អាហ្នឹងមានបញ្ហា លើខ្លួនយើងថាយើងចេះ តែមានករណីមួយ ករណីពីរចេះចុះមួយ ។ អាហ្នឹងគេប្រើទៅណា ទៅៗតាមផែនការរបស់គេ ទៅធ្វើដូចដល់ពេលដល់ថ្ងៃទៅយើងត្រឡប់មកវិញទៅ មានបញ្ហា អីដល់... ។

ធានី ៖ ចឹងលោកតាក្រោយពីរៀបគ្រួសារហើយទៅណាទៀតទៅ?

លឿម ៖ បាទ! ខ្ញុំអត់បានទៅណាទេ រៀបគ្រួសារហើយទៅធ្វើការធ្វើស្រែ ក៏ដល់អាពេល ។

ធានី ៖ ជួបគ្រួសារហើយរាល់ថ្ងៃដែរ ជួបគ្នាពេលល្ងាចដែរ?

លឿម ៖ អត់មានធ្វើអីទេៗ ធ្វើតែស្រែពីសម័យនោះមក មិនដែលបានធ្វើស្អីៗហ្នឹងគេផង ។

ធានី ៖ ចុះលោកតាថាលោកតាធ្វើកងសេនាជនហ្នឹងធ្វើពេលណា?

លឿម ៖ ខ្ញុំធ្វើអាសម័យក្រោយ ។

ធានី ៖ អូ! ក្រោយទៀត ពេលណាដែរចាំមើលលោកតារៀបគ្រួសារហើយ បន្ទាប់មកធ្វើស្រែដល់ ពេលណាបានយួនចូល?

លឿម ៖ បាទៗហ្នឹងឯង យួនចូលមក បែកៗ ។

ធានី ៖ ពេលណាទៅឆ្នាំប៉ុន្មាន?

លឿម ៖ យួនចូលមកវាឆ្នាំ១៩៧៩ ។

ធានី ៖ ៧៩?

លឿម ៖ បាទ! ១៩៧៩បានបែក ។

ធានី ៖ បែកទៅណាទៅ?

លឿម ៖ បានបែករត់ចេញពីភូមិនេះទៅនៅនោះ ។

ធានី ៖ នៅណាវិញ?

លឿម ៖ នៅអែបស្វាយ សាលាក្រៅ ។

ធានី ៖ រត់ទៅ?

លឿម ៖ បាទ!

ធានី ៖ ពេលចេញពីភូមិនេះទៅ គេដេញឬម៉េច?

លឿម ៖ ជម្លៀលៗខ្មែរក្រហម ។

ធានី ៖ អូ!ខ្មែរក្រហម?

លឿម ៖ បាទ!ជម្លៀលខ្មែរក្រហម ។

ធានី ៖ ខ្មែរក្រហម លោកតារត់ទៅ?

លឿម ៖ ជម្លៀលៗទាំងភូមិមិនមែនជម្លៀលតែខ្ញុំ ពួកអ្នកជម្លៀសគេទៅនៅតាមខ្មែរក្រហមទៅ ។

ធានី ៖ តែលោកតារត់ទៅតាមខ្មែរក្រហម?

លឿម ៖ បាទ! ខ្ញុំអត់ទៅតាម ខ្ញុំបែកទៅនេះវិញ ។

ធានី ៈ   វត់ទៅ?

លឿម ៈ បាទ! បែកទៅរកវៀតណាមវិញ ។

ធានី ៈ   ចុះបន្ទាប់មកលោកតាធ្វើសេនាជនហ្នឹងធ្វើពេលណាវិញ?

លឿម ៈ សេនាជននេះខ្ញុំធ្វើអាសម័យយើងហេងសំរិនហ្នឹង ។

ធានី ៈ   ពេលចូលយួនហ្នឹង?

លឿម ៈ បាទ!

ធានី ៈ   យួនហ្នឹងលោកតាធ្វើជាសេនាជន?

លឿម ៈ បាទ!

ធានី ៈ   សេនាជននៅភូមិយើងនេះ?

លឿម ៈ អត់ទេ ធ្វើនៅក្រោម ។

ធានី ៈ   នៅណាវិញ?

លឿម ៈ នៅបាត់ដំបង ។

ធានី ៈ   នៅបាត់ដំបង នៅភូមិឃុំអីគេ?

លឿម ៈ នៅតាក្រៀម ខ្ញុំធ្វើនៅតាក្រៀម ។

ធានី ៈ   តាក្រៀវ?

លឿម ៈ បាទ! តាក្រៀម ។

ធានី ៈ   ភូមិអីគេ ឃុំអីគេ?

លឿម ៈ ភូមិអូរតាញា ។

ធានី ៈ   តាញា តាញាណេ?

លឿម ៈ តាញា ។

ធានី ៈ   ហើយឃុំអីទៅ?

លឿម ៈ ឃុំតាក្រៀម ។

ធានី ៈ   ស្រុកអីទៅ?

លឿម ៈ ស្រុកបាណន់ ខេត្តបាត់ដំបង ។

ធានី ៈ   នៅកងសេនាជន នៅប៉ុន្មានឆ្នាំ?

លឿម ៈ បានប្រហែល២ឆ្នាំ ។

ធានី ៈ   ២ឆ្នាំទៅណាទៀត?

លឿម ៖ បានប្រហែល២ឆ្នាំ គេទាញខ្ញុំមកធ្វើក្រុមវិញ ។

ធានី ៖ ក្រុម?

លឿម ៖ បាទ!ធ្វើក្រុម ។

ធានី ៖ ធ្វើក្រុមហ្នឹងម៉េចទៅ?

លឿម ៖ ធ្វើក្រុមក្តាប់ក្នុងភូមិ ក្នុងក្រុម ក្តាប់ក្នុងភូមិប៉ុន្មានគ្រួសារៗចេះទៅ ។

ធានី ៖ ធ្វើភូមិ ហើយក្រុម?

លឿម ៖ ធ្វើក្រុម ។

ធានី ៖ មិនមែនមេភូមិទេ?

លឿម ៖ ទេ!

ធានី ៖ អាហ្នឹងលោកតាក្តាប់ប៉ុន្មានគ្រួសារ?

លឿម ៖ ក្តាប់១០គ្រួសារ សម្រាប់ដឹកនាំធ្វើការដឹកប្រឡាយអីហ្នឹងដែរ ។

ធានី ៖ នៅតាក្រៀមហ្នឹងដែរ?

លឿម ៖ បាទ! នៅអូរតាញា នៅតាក្រៀម ភូមិតាក្រៀម ។

ធានី ៖ ហើយបន្ទាប់មកទៀតលោកតាថាក-៥យ៉ាងម៉េច ដូចថាគេប្រាប់ម៉េច??

លឿម ៖ បាទ!ក-៥ហ្នឹងខ្ញុំគេចៗឯក្រុម ខ្ញុំមើលទៅពិបាកអារឿងប្រើបងប្អូនអាពេលហ្នឹងខ្ញុំគេចៗខ្លួន ថាឲ្យផុតៗពីក្រុមឈប់ប្រើកូនក្រុម ខ្ញុំគេចទៅគេឲ្យខ្ញុំទៅក-៥ ។

ធានី ៖ ទៅក-៥ហ្នឹងទៅកន្លែងណា លោកតាអ្នកដឹកនាំទៅក-៥ ឬលោកតាទៅក-៥?

លឿម ៖ អត់ទេ គេដឹកនាំទៅ មេភូមិដឹកនាំទៅ ។

ធានី ៖ ហើយទៅក-៥ទៅកន្លែងណាទៅ?

លឿម ៖ ទៅក្រវ៉ាញ ។

ធានី ៖ ទៅក្រវ៉ាញ?

លឿម ៖ បាទ!

ធានី ៖ នៅឆ្នាំប៉ុន្មាន?

លឿម ៖ នៅឆ្នាំ១៩៨១ ៨២ ។

ធានី ៖ ៨១ ៨២ ទៅក្រវ៉ាញ?

លឿម ៖ បាទ!

ធានី ៖ ទៅក្រវ៉ាញទៅធ្វើអីគេ?

លឿម ៖ ទៅឆ្ការផ្លូវ លីឈើធ្វើស្ពាន ឈើប្រវែងសុទ្ធតែ៤ម៉ែត្រលីដាក់អូរៗធ្វើផ្លូវឆ្លង ។

ធានី ៖ គេធ្វើក-៥ធ្វើៗអី?

លឿម ៖ ក-៥គេកំនែនពួកគាត់ហ្នឹងឯង កំនែនពួកគាត់ឲ្យយកទៅឆ្ការព្រៃឆ្ការផ្លូវដើម្បីយកឈើដាក់ធ្វើ
ស្ពានឲ្យរថក្រោះឲ្យឡានបើកយកអីវ៉ាន់ចេញពីក្រវ៉ាញមក ។

ធានី ៖ អាហ្នឹងនៅក-៥ នៅខ្មែរក្រហម ឬក៏នៅយើង?

លឿម ៖ បាទ! យកនៅក្រវ៉ាញហ្នឹងឯង ហើយពួកវៀតណាមវ៉ៃបាន ។

ធានី ៖ យកអីវ៉ាន់ឡើងពីខ្មែរក្រហម?

លឿម ៖ បាទ! យកអីវ៉ាន់ពីខ្មែរក្រហម ដឹកជញ្ជូនចេញ ។

ធានី ៖ ហើយលោកតាភ័យខ្លាចអត់ ព្រោះខ្មែរក្រហមផង វៀតណាមផង យើងនៅកណ្តាល?

លឿម ៖ បាទ!

ធានី ៖ មានការវ៉ៃគ្នាចឹងទេ?

លឿម ៖ ទេ! អារឿងចេះបើសិនជាគេវ៉ៃយើងនៅឧទាហរណ៍យើងនៅខាងវៀតណាម យើងនៅខាង
វៀតណាម ព្រោះវាដែលប្រទូរំអី ។

ធានី ៖ អាចប្រទូរំដែរតា?

លឿម ៖ ទេ!អត់ ព្រោះគេយកទៅវាដឹងកំណត់យើង ថាកម្ពុជាប៉ុននេះដែលមកធ្វើការនៅកន្លែងនេះ ។

ធានី ៖ តែមានប៉ុន្មាននាក់ ដែលទៅហើយអត់បានមកវិញ?

លឿម ៖ ទៅច្រើនក្នុងម៉ាខេត្តបាត់ដំបងទៅច្រើន ។

ធានី ៖ ទៅច្រើន មានអត់បានមកទេ?

លឿម ៖ បានមកតើ បានមកវិញ ។

ធានី ៖ មានអ្នកខ្លះស្លាប់ មានអីចឹង?

លឿម ៖ អត់ទេ មានតែកំបុតជើងតែប៉ុនហ្នឹង ។

ធានី ៖ ជាន់មីន?

លឿម ៖ បាទ! មានតែជាន់មីន កំបុតជើង ។

ធានី ៖ ចុះមានគ្រុនចាញ់មានអី?

លឿម ៖ គ្រុនចាញ់ ខ្ញុំក៏គ្រុនចាញ់ដែរ ។

ធានី ៖ មានថ្នាំគេឲ្យលេបមុន កុំឲ្យគ្រុនចាញ់?

លឿម ៖ បាន ដល់មកវិញបានពេទ្យគេព្យាបាលវាអត់បាត់អស់លុយ  គេជួយៗព្យាបាលក្នុងបាត់ដំបង
នេះ គេជួយ ។

ធានី ៖  លោកនៅប៉ុន្មានក-៥?

លឿម ៖ ខ្ញុំនៅ១០ឆ្នាំ ។

ធានី ៖  ១០ឆ្នាំ?

លឿម ៖ ទេ! អាហ្នឹងខ្ញុំទៅ៣ខែ ។

ធានី ៖  ក-៥ទៅ៣ខែ?

លឿម ៖ ទៅ៣ខែ ខ្ញុំទៅ៣ខែ ។

ធានី ៖  បន្ទាប់មកទៀត នៅធ្វើអីគេទៀតនៅបាត់ដំបងហ្នឹង?

លឿម ៖ ខ្ញុំអត់បានទៅណាទេ ធ្វើតែស្រែប៉ុនហ្នឹងឯង ។

ធានី ៖  ចុះលោកតាថា១០ឆ្នាំនៅធ្វើការរហូត?

លឿម ៖ អត់ទេ ដល់ពេលហ្នឹងធ្វើដែលប៉ុនធ្វើនៅក្នុងកំឡុងក្រុមហ្នឹង ធ្វើដដែល ។

ធានី ៖  ធ្វើអីគេក្រុម?

លឿម ៖ មានធ្វើអីគ្រាន់តែគេដាក់ផែនការមកឲ្យបងប្អូនទៅធ្វើការពលកម្មត្រង់ណា  គ្រាន់ប្រើប្រាស់តែ
គេតែប៉ុននោះទេ មានតែប្រើតែគេ ខ្លួនឯងទៅផងដែរហ្នឹង ឲ្យទៅយាមណាបានខ្លាចគេថាឯង
ប្រើតែគេ ទៅដែរតើ ។

ធានី ៖  ចុះលោកតាម៉េចបានមកដល់នេះ?

លឿម ៖ ម្ដាយខ្ញុំនៅហ្នឹងគាត់ឈឺៗបានគាត់ផ្ញើសំបុត្រ  បានខ្ញុំវិលបកមកនេះវិញ ។

ធានី ៖  ឆ្នាំប៉ុន្មានដែលលោកតាត្រឡប់មកស្រុកនេះវិញ?

លឿម ៖ ៨៣  ១៩៨៣ ។

ធានី ៖  ៨៣ត្រឡប់មកនេះវិញ?

លឿម ៖ បាទ! ៨៣ ។

ធានី ៖  ហើយចឹងលោកតានៅពី៨៣មករហូត ចុះលោកតាសូម្បីតែប៉ុរ៉ាអីក៏ធ្វើស្អីក៏ធ្វើណា?

លឿម ៖ អានោះជួយៗគេដែលមកវិញហើយ  ដែលមកវិញហើយជួយគេៗ  បើមិនជួយគេណាបើគេ
ប្រើហើយ ។

ធានី ៖  ជួយគេម៉េច?

លឿម ៈ មិនថាប្អូនឯង មិនថាខ្ញុំឲ្យចេះមើលទៅខាងដូចយ៉ាងសន្តិសុខ ដូចថាការដឹកជញ្ជូនដឹកស្អី២-៣ បើយើងមិនតាមគេ ដល់ហើយខ្លាចយើងនេះទៀតគេថាយើងទៀត ។

ធានី ៈ ប៉ុវ៉ាហើយខាងណាលោកតា?

លឿម ៈ ខាងណាទេ ខាងប៉ុវ៉ាខាងនេះ ខាងតាសឺន សានៗ ។

ធានី ៈ តាសឺនសាន នៅខាងប៉ុវ៉ា?

លឿម ៈ បាទ!

ធានី ៈ ហើយមានខាងណាផ្សេងទៀតទេ នៅភូមិយើងនេះដែលមក ។ នៅភូមិយើងនេះមានខាងផ្សេងទៀតក្រៅពីប៉ុវ៉ា?

លឿម ៈ ទេ! មិនមានទេ មិនមានអ្នកណានៅហ្នឹងទេ ប៉ុន្តែបើអ្នកបម្រើមីងមានគេមានៗនៅក្នុងស្រុកក្នុងភូមិនេះ ។

ធានី ៈ មានតែប៉ុវ៉ាមួយទេ លោកតា?

លឿម ៈ បាទ!

ធានី ៈ ដែលនៅភូមិយើងនេះ មកដល់នេះ?

លឿម ៈ បាទ!

ធានី ៈ ហើយប៉ុវ៉ាគាត់មកធ្វើអីគេ?

លឿម ៈ ចុះគេថាចុះមករំដោះប្រទេសជាតិដែរ ដឹងណាបើនោះថាគេមិនចូល ដល់យើងនេះថាគេមករំដោះប្រទេសជាតិដែរ គេមកជួយខ្មែរដែរ ។ អានោះគេថាជួយខ្មែរដែរ ។

ធានី ៈ ចុះមានការវ៉ៃគ្នាអត់?

លឿម ៈ វ៉ៃតើ ។

ធានី ៈ លោកតានៅខាងប៉ុវ៉ាចឹងគេមិន?

លឿម ៈ ទេ! ខ្ញុំនៅក្នុងភូមិខ្ញុំប្រជាជនទៅវិញតើ ខ្ញុំមាននេះណា ។

ធានី ៈ គ្រាន់តែគេឲ្យធ្វើអីយើងធ្វើតាមគេទៅ?

លឿម ៈ បាទ! ហ្នឹងឯង យើងគ្រាន់តែជួយគេតែប៉ុនហ្នឹងឯង ។

ធានី ៈ ជួយធ្វើអីខ្លះ?

លឿម ៈ គ្រាន់តែជួយយកអានេះអានោះ ឲ្យគេជញ្ជូនឲ្យគេប៉ុណ្ណោះដូចគ្នា យើងឲ្យគេហើយយើងមកផ្ទះវិញទៅ គ្មានបញ្ហា ។ មិនមែនថាយើងទៅនៅត្រាំត្រែងនៅហ្នឹងគេណា ។

ធានី ៈ ចុះលោកតានៅម្តុំយើង កាលហ្នឹងខ្មែរក្រហមភាគច្រើនមកនៅហ្នឹង?

លឿម ៖ បាទ! នៅតើ ។

ធានី ៖ នៅចំរុះគ្នា?

លឿម ៖ នៅចំរុះគ្នា ជួនចេះ ចាំមើលខ្ញុំនិយាយ ។ ជួនណាទៅខ្មែរក្រហមគេមកទៅ ដល់ពេលយើងឧទាហរណ៍ថាបើយើងនៅក្នុងភូមិ បើយើងមិនរែកពន្ធដល់ហើយវាយ៉ាប់ ដល់ហើយទៅយើងមានអង្ករ មានជាម្ហូបមានជាស្អីទេ យើងឲ្យគេទៅ ចែកគេទៅ ។ ឲ្យគេទៅឲ្យគេយកទៅស៊ីណា អីណែស៊ីតាមតែគេទៅ ។ ហ៎! បើខាងក្នុងមកក៏ចឹងគេត្រូវការស្អី ត្រូវការមាន់ត្រូវការទា ក៏ យើងរកឲ្យគេទៅៗក៏ទៅៗ គេមាននេះណា ។ ហ៎! ដូចប៉ាវ៉ាមកក៏គេត្រូវរក គេត្រូវធ្វើស្អី យើងធ្វើទៅ ប៉ុននេះឯងគ្មានស្អីអត់មានរឿងអីទេមានតែប៉ុនហ្នឹង ។ ហើយយើងប្រជាជន

នៅប្រជាជន ។

ធានី ៖ តែលោកតាត្រឹមមេ ត្រឹមក្រុម ប៉ុន្តែអាចរកចឹងៗបានដែរ ។ តែអាហ្នឹងច្រើនតែមេឃុំ មេភូមិគេអ្នកចាត់ចែងតើ?

លឿម ៖ គេអ្នកចាត់ចែងតើ យើងគ្រាន់តែទទួលបញ្ជាពីគេតើ អត់មាននេះទេ ។

ធានី ៖ យើងទទួលបញ្ជាពីមេឃុំ មេភូមិ?

លឿម ៖ បាទ! មេភូមិៗ ។

ធានី ៖ មេភូមិគេឈ្មោះអីគេលោកតា មេភូមិនៅយើង?

លឿម ៖ បាទ! ឧទាហរណ៍ថាមេឃុំណា គាត់ថាបើរឿងយើងដោះស្រាយនេះ យើងគ្រាន់ថាមិនបាច់ដល់មេភូមិទេ ព្រោះយើងកាលណាយើងឲ្យមេឃុំ មេភូមិគេដឹងវាអត់បានណា ។ ដល់ហើយភូមិយើងបើយើងមិនដោះស្រាយ តើឲ្យយើងទុកនៅម៉េចកើតចេះ ។

ធានី ៖ តែកាលនៅសម័យហ្នឹងមេភូមិឈ្មោះអីគេ មេភូមិឈ្មោះអីលោកតាដឹង?

លឿម ៖ បាទ! សព្វថ្ងៃនេះហើយ ។

ធានី ៖ ឈ្មោះអីគេ?

លឿម ៖ ឈ្មោះ តាព្រែក ។

ធានី ៖ តាព្រែកមេឃុំ?

លឿម ៖ ទេ! មេភូមិ ។

ធានី ៖ មេភូមិដន្ទៀសដៃ?

លឿម ៖ ឈ្មោះតាព្រែក បាទ! បើគាត់មិនដោះស្រាយឲ្យចប់ បើគាត់មិនប្រើយើងឲ្យសុំអង្ករ សុំឲ្យលួចលាក់បានឲ្យគេម៉េចទុកគេនៅនេះហើយ ។ បើពេលខាងក្នុងគេមក បើសិនណាមកទាន់គេមិនវៃយើងនៅនេះ ។ ដល់ហើយយើងដោះស្រាយចេះៗទៅ គេទៅបាត់ទៅពីនោះមកធម្មតាគេសួរទៅរកគេ បើប៉ះណាក្រោយៗទៅតាមតែគេ ។

ធានី ៖ ចឹងនៅឆ្នាំណាប៉ុន្មាន ដែលនៅភូមិយើងមានសន្តិភាព លែងមានជម្លោះ លែងមានអ្នកណាបំពានតាម.....?

លឿម ៖ មានសន្តិភាពមកពីឆ្នាំ៩១ ៩២ ។

ធានី ៖ ៩១ ៩២លែងមានចឹងហើយ?

លឿម ៖ បាទៗ ។

ធានី ៖ អស់ៗប៉ាវ៉ា អស់ខ្មែរក្រហមហើយ?

លឿម ៖ បាទៗ ដែលសន្តិភាព ។

ធានី ៖ អូ! លែងរញ៉េរញ៉ៃចឹងទៀត យើងអាចរកស៊ីបាន?

លឿម ៖ បាទៗ ចំមើលប៉ុន្មានឆ្នាំ ៩១ ៩២ ។

ធានី ៖ គ្រួសារលោកតាឈ្មោះអីគេ?

លឿម ៖ ឈ្មោះ ជុំ ហួន ។

ធានី ៖ លោកតារាល់ថ្ងៃមានកូនប៉ុន្មាននាក់ដែរ?

លឿម ៖ ខ្ញុំកូន៧នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

លឿម ៖ ស្រី៤នាក់ ប្រុស៣ ។

ធានី ៖ ចុះលោកតាសព្វថ្ងៃមានការងារធ្វើអីខ្លះដែរ មានមុខងារជាអី?

លឿម ៖ ខ្ញុំគ្មានស្អីទេ សព្វថ្ងៃនៅតែក្រុម ។

ធានី ៖ ក្រុមដដែល?

លឿម ៖ បាទ! នៅតែក្រុមៗ ។

ធានី ៖ ក្រុមក្នុងភូមិយើងហ្នឹង?

លឿម ៖ បាទ! ក្រុមក្នុងភូមិយើងដែលនៅសព្វថ្ងៃ ។

ធានី ៖ ក្រុមហ្នឹងធ្វើការងារអីខ្លះទៅ?

លឿម ៖ ទេ! គ្មានធ្វើការងារអីទេ បើមើលតួយ៉ាងធ្វើថ្នល់ធ្វើអីក៏មានដើររៃអង្គាស់ប្រាក់គេស្អីគេត្រូវ ដែនការគេប្រាប់តែយើង គេយកប្រាក់ប៉ុន្មានៗដើរសុំប្រាក់គេហ្នឹងឯង ។ សព្វថ្ងៃប៉ុន្មានឡើង ១៧គ្រួសារ ហ៎!គេត្រង់នោះប៉ុន្មាន២០គ្រួសារទៅ ។

ធានី ៖ ចុះលោកនៅក្រុមទីប៉ុន្មាន?

លឿម ៖ ខ្ញុំក្រុមទី២ ។

ធានី ៖ ប្រធានក្រុមទី២?

លឿម ៖ បាទ! សព្វថ្ងៃនេះចេះឯង ដូចថាពីមុនចេះឯង មិនដែលបានធ្វើការអីធំពីណាទេ ខ្លួនខ្ញុំប៉ុននេះ ទៅហើយ ចង់បានធំៗមិនកើតនៅតែប៉ុននេះ ។

ធានី ៖ ចឹងក្រៅពីការងារហ្នឹង ធ្វើស្រែចំការ?

លឿម ៖ បាទ!ធ្វើស្រែចំការ អាពេលលោកពេលអី មានតែរៃអង្គាស់បងប្អូនដែលមរណ ១០០០ រៀល ហើយអង្ករម៉ាកំប៉ុង២កំប៉ុង រួមផ្សំគ្នាគេខាងនោះក៏បាន វត្តតែប៉ុនហ្នឹងឯងអត់មានស្អី

ធានី ៖ ចុះលោកតាយល់យ៉ាងម៉េចដែរ កាលពីមុនហើយឥឡូវ វាខុសគ្នាយ៉ាងម៉េចទៅ ការរស់ នៅ?

លឿម ៖ គេបានសន្តិភាពចេះទៅមានអី វាស្រួល វាអត់មានការរំពើកៗថាម៉េចៗ ព្រោះវាតែម៉ាមុខ សញ្ញា តែវាអត់នេះ ។ ចឹងកាលមុនវាមានឡើង៣មុខសញ្ញា ហ៎!នោះថាខាងក្នុងវៀតណាម ផង ហ៎!ខាងក្រៅណាខ្មែរក្រហមផង ប៉ាវ៉ាផង ។ ហើយយើងនៅជនបទ បើយើងមិនចេះ រកពន្ធ បើសិនយើងទុកឲ្យត្រឹង ក្នុងភូមិចេះសល់ អត់សល់ទេឆេះទាល់តែខ្ទេចគ្មានសល់ទេ ។ ចុះអាសល់ឆេះប៉ុននោះគ្រាន់ ថាអាវាស្លាប់ចង់មនុស្សប្រជាជនទៅទៀតគ្មានសល់ អាបើ យើងបានដោះស្រាយចាស់ៗចេញទៅវាផុតយើងបាត់ហើយអត់មានបញ្ហា ។ យើងសុំឲ្យគេ ចេញទៅក៏គេចេញដែរ បើយើងមិនមានស្អីឲ្យគេក៏គេនៅហ្នឹងដែរ គេអត់ទៅបើសិនអ្នកខាង ក្នុងមកក៏គ្មានស្អីរើកំទេច អត់មានបញ្ហាទេ មានតែរឿងប៉ុនហ្នឹងឯង អត់មានបញ្ហាអី មិនថាប៉ាវ៉ា មិនថាខ្មែរក្រហមទេ ។ បើថាខាងក្នុងមកនៅនេះនៅហ្នឹងរយៈប៉ុន្មាន ម៉ាខែ២ខែ ទៅ បើថាក្រៅនោះវាមកមិនដឹងអី វារើតែគ្នាវាទៅ វាអត់ប៉ះពាល់ដល់យើងផង មានតែ ប៉ុនហ្នឹង ។

ធានី ៖ ចុះលោកតាមានអីចង់សួរខ្ញុំវិញទេ ឬមានអ្វីដែលខ្ញុំអត់បានសួរ?

លឿម ៖ មិនមានមតិអីនឹងជួយ ។

ធានី ៖ លោកតាដែលស្គាល់ហង្ស ពិនទេ? ស្គាល់តាពិន?

លឿម ៖ តាពិននៅណា?

ធានី ៖ តាពិននៅផ្កាំ?

លឿម ៖ ហង្ស ពិន ស្គាល់យូរហើយ ប៉ុនសព្វថ្ងៃមិនដឹងគាត់ទៅណា ។

ធានី ៖ ដឹងគាត់ធ្វើអីគេ កាលសម័យខ្មែរក្រហម?

លឿម ៖ ទេ! មិនដឹងគាត់ធ្វើអីផង ព្រោះរាល់ថ្ងៃនោះឮថាគាត់ធ្វើគ្រូៗ ឮតែគេហៅគ្រូពិនៗ ប៉ុន្តែ ។

ធានី ៖ ក្រៅពីហ្នឹងអត់ដឹង?

លឿម ៖ បាទ! ខ្ញុំមិនដឹងថាគាត់ធ្វើអី ។

ធានី ៖ គ្រូហ្នឹងគាត់ម៉េចបានម្នាក់ៗស្គាល់គាត់គ្រប់គ្នា?

លឿម ៖ បាទ! ដែលគាត់មិនស្គាល់បើគាត់ធ្វើគ្រូ ។ ដូចប្អូនឯងធ្វើគ្រូចេះ ខ្ញុំធ្លាប់ឃើញៗ ។

ធានី ៖ តែអត់ដឹងរឿងគាត់ម៉េច?

លឿម ៖ បាទ! អត់ដឹងថារឿងគាត់ម៉េច ។

ធានី ៖ ចា៎! ព្រោះតាពិនហ្នឹង រាល់ថ្ងៃគាត់នៅភ្នំពេញ ។

លឿម ៖ បាទ!

ធានី ៖ គេចាប់គាត់ដាក់នៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គាត់ហ្នឹងឈ្មោះហង្ស ពិន ហៅ តាមពិតឈ្មោះគាត់ពិត ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅឌុច តែគាត់ដូរមកយើងនេះ គាត់ដូរដាក់ហង្ស ពិន ទៅបានស្គាល់គាត់ ។ ហើយគាត់ជាប្រធានគុកទួលស្លែង កាលសម័យខ្មែរក្រហម ។

លឿម ៖ អូ!

ធានី ៖ ចឹងអត់មានអីចង់សួរខ្ញុំទៀតទេលោកតា?

លឿម ៖ បាទ! ទេ ខ្ញុំស្មានតែគាត់នោះរស់នៅតែហ្នឹងផ្កាំ ខ្ញុំឮឈ្មោះគាត់ដែរ ស្មានតែអញ្ជើញទៅណាទៅណែហើយ ។ ប៉ុនអារឿងដែលគាត់ទៅណាទៅឆ្ងាយៗហ្នឹង ខ្ញុំអត់ដឹងរឿងគាត់ទេ ខ្ញុំមិនដឹង រឿងគាត់ទេ ។

ធានី ៖ ចា៎! ចឹងអត់អីទេចឹង លោកតាចៅអរគុណច្រើនហើយ ។

«ចប់»